# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**..៥០...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយដេប៉ាតឺម៉ង់ថ្នាក់ក្រោយឧត្តមសិក្សា ទៅជាវិទ្យាស្ថានក្រោយឧត្តមសិក្សា

---

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា

-តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១ៈ-**

ត្រូវបានប្រែក្លាយ ដេប៉ាតឺម៉ង់ថ្នាក់ក្រោយឧត្តមសិក្សា ទៅជា វិទ្យាស្ថានក្រោយឧត្តមសិក្សា សរសេរកាត់ "វ.ក.ឧ" ជាភាសាអង់គ្លេស "Institute of Graduate Study" ចំណុះបណ្ឌិត្យសភានគរបាលកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២.-**

វិទ្យាស្ថានក្រោយឧត្តមសិក្សាមានឋានៈស្មើ នាយកដ្ឋាន។ វិទ្យាស្ថានក្រោយឧត្តមសិក្សា ដឹកនាំដោយ នាយក មួយរូប និងនាយករង មួយចំនួន ជាជំនួយតាមការចាំបាច់ ។

**មាត្រា៣.-**

វិទ្យាស្ថានក្រោយឧត្តមសិក្សា មានតួនាទីធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង ថ្នាក់បណ្ឌិត ជូនដល់កងកម្លាំងនគរបាលជាតិ និស្សិត និងមន្ត្រីរាជការ លើមុខជំនាញជាអាទិ៍: នីតិសាស្ត្រ វិទ្យាសាស្ត្រនយោបាយ គ្រប់គ្រង រដ្ឋបាលសាធារណៈ និងមុខជំនាញដទៃទៀតតាមការវិវត្តរីកចម្រើន របស់វិទ្យាស្ថាន ។

**មាត្រា៤.-**

ការរៀបចំតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់វិទ្យាស្ថានក្រោយឧត្តម ត្រូវកំណត់ដោយប្រកាសរបស់ ក្រសួងមហាផ្ទៃ ។

**មាត្រា៥.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និង ស្ថាប័ន ដែលមានការ ពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៦
-ឯកសារ-កាលប្បវត្តិ